**ប្រការ ២** ៖ ត្រូវបានកែសម្រួលសមាសភាពក្រុមការងារបច្ចេកទេសអនុវត្តគម្រោងគ្រប់គ្រងធនធានទឹកចម្រុះអាងស្ទឹងសែន មានសមាសភាព ដូចខាងក្រោម៖

| | | | |
|---|---|---|---|
| ១. ឯកឧត្តម | **លឹម ពុយ** | អនុប្រធាន អាជ្ញាធរទន្លេសាប | ប្រធាន |
| ២. ឯកឧត្តម | **សរ គឹមសាន្ត** | អគ្គលេខាធិការ អាជ្ញាធរទន្លេសាប | អនុប្រធានអចិន្ត្រៃយ៍ |
| ៣. ឯកឧត្តម | **ជា សុខនី** | អគ្គលេខាធិការរង អាជ្ញាធរទន្លេសាប | អនុប្រធាន |
| ៤. លោកស្រី | **ប្រាក់ ចាន់ខន្ធនា** | អនុប្រធាននាយកដ្ឋានធនធានធម្មជាតិ | សមាជិក |
| ៥. លោក | **ប៊ុន ទុន្សី** | អនុប្រធាននាយកដ្ឋានធនធានធម្មជាតិ | សមាជិក |
| ៦. លោក | **ខ្វាន់ តុន្តា** | អនុប្រធាននាយកដ្ឋានធនធានធម្មជាតិ | សមាជិក |
| ៧. លោក | **នួប សំណាង** | ប្រធានការិយាល័យផ្សព្វផ្សាយព័ត៌មាន | សមាជិក |
| ៨. លោក | **ខូច ទេវសុខ** | ប្រធានការិយាល័យធនធានរ៉ែ | សមាជិក |
| ៩. លោក | **សុខ វ៉ាយ៉ុង** | ប្រធានការិយាល័យអភិរក្ស | សមាជិក |

**ប្រការ ៣** ៖ ក្រុមការងារគម្រោងគ្រប់គ្រងធនធានទឹកចម្រុះអាងស្ទឹងសែន មានតួនាទី និងភារកិច្ច ដូចខាងក្រោម ៖

- ដឹកនាំ និងសម្របសម្រួលដល់ការអនុវត្តគម្រោងគ្រប់គ្រងធនធានទឹកចម្រុះអាងស្ទឹងសែន
- កំណត់បទដ្ឋានបច្ចេកទេស និងវិធីសាស្ត្រសិក្សាស្រាវជ្រាវលើការគ្រប់គ្រងធនធានទឹកចម្រុះ ដើម្បីរៀបចំផែនការ នៃការប្រើប្រាស់ធនធានទឹកនៃអាងស្ទឹងប្រកបដោយនិរន្តរភាព
- ទទួលខុសត្រូវ និងអនុវត្តគម្រោងឲ្យបានត្រឹមត្រូវតាមលក្ខណៈបច្ចេកទេសប្រកបដោយគុណភាព និងប្រសិទ្ធភាពខ្ពស់ ហើយធានាបាននូវសុក្រិតភាព
- រៀបចំរបាយការណ៍វឌ្ឍនភាពអនុវត្តគម្រោង ជូនថ្នាក់ដឹកនាំ អាជ្ញាធរទន្លេសាប
- អនុវត្តរាល់ការងារ និងភារកិច្ចផ្សេងៗទៀត ដែលឯកឧត្តមរដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម និងជាប្រធានអាជ្ញាធរទន្លេសាប ប្រគល់ជូន ។

**ប្រការ ៤** ៖ សាមីជនដូចមានចែងក្នុងប្រការ ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ថ្ងៃ អង្គារ ៩ រោច ខែ អស្សុជ ឆ្នាំ ថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែ វិច្ឆិកា ឆ្នាំ ២០២៣

**រដ្ឋមន្ត្រី**

**និងជា ប្រធានអាជ្ញាធរទន្លេសាប**

ថៅ_វេជ្ជា

**ចម្លងជូន ៖**

- ក្រសួងធនធានទឹក និងឧតុនិយម
- ខុទ្ទកាល័យឯកឧត្តមរដ្ឋមន្ត្រី
- ការិយាល័យអន្តរជាតិភ្នាក់ងារទឹកបារាំង
- ទីភ្នាក់ងារបារាំងសម្រាប់ការអភិវឌ្ឍន៍ AFD
  "ដើម្បីជូនជ្រាប"
- ដូចក្នុងប្រការ ២ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ